ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ : ......២៣៩៥....ពស.........

ថ្ងៃចន្ទ ១៣រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២ ខែ តុលា ឆ្នាំ២០២៣

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## ពិធីដាក់ដំណើរការជាផ្លូវការនៃ "កម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល" និងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងការជំរុញការអភិវឌ្ឍជំនាញឌីជីថល

នាព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣ នៅទីស្ដីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) ឯកឧត្ដម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រី **ក.ប.ទ.** បានអញ្ជើញជាអធិបតីក្នុងពិធីដាក់ដំណើរការជាផ្លូវការនៃ "កម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល" និងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងការជំរុញការអភិវឌ្ឍជំនាញឌីជីថល រវាង **ក.ប.ទ.** និងគ្រឹះស្ថានឧត្ដមសិក្សាដៃគូទាំង៦ ដែលរួមមាន បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យជាតិគ្រប់គ្រង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ និងសាកលវិទ្យាល័យជាប៉ាហ្គុន ព្រមទាំងមានការអញ្ជើញចូលរួមពីឯកឧត្ដម លោកជំទាវ ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ អង្គភាពចំណុះ **ក.ប.ទ.** តំណាងគ្រឹះស្ថានឧត្ដមសិក្សាដៃគូទាំង៦ តំណាងវិស័យឯកជន និងអង្គភាពសារព័ត៌មាន ដែលមានចំនួនសរុបប្រមាណ ៣០០នាក់។

នៅក្នុងឱកាសនោះ លោកជំទាវ **ហ៊ាន ប៉ូលីណា** អនុរដ្ឋលេខាធិការ **ក.ប.ទ.** បានជម្រាបជូនអំពីសារតារនៃការបង្កើត "**កម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល**" (**ក.អ.ជ.ឌ.**) និងមានឈ្មោះជាភាសាអង់គ្លេសថា "Digital Skill Development Program" (DSDP) ក្នុងកម្មវត្ថុចម្បងចំនួន៣ ដែលរួមមាន៖ (១) ការចូលរួមអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ (២) ការលើកកម្ពស់ស្តង់ដាគុណវុឌ្ឍិនៃការអប់រំលើមុខជំនាញដែលទាក់ទងនឹងបច្ចេកវិទ្យាឌីជីថល និង (៣) ការគាំទ្រដល់ដំណើរការអភិវឌ្ឍមូលធនមនុស្សឌីជីថល តាមរយៈការផ្ដល់ឱកាសសម្រាប់ការអភិវឌ្ឍជំនាញឌីជីថល និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបម្រើដល់ការអប់រំ។ បន្ថែមលើនេះ ឯកឧត្ដម **ហោ ប៉េង** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង បានលើកឡើងថា ក្នុងនាមជាតំណាងគ្រឹះស្ថានឧត្ដមសិក្សាដៃគូទាំង៦របស់ **ក.ប.ទ.** ដែលឆ្លុះបញ្ចាំងពីការប្ដេជ្ញារបស់គ្រឹះស្ថានឧត្ដមសិក្សាដៃគូ ក្នុងការចូលរួមលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួងលើការបន្តជំរុញការអប់រំពាក់ព័ន្ធនឹងជំនាញឌីជីថលនៅកម្ពុជា។

ថ្លែងក្នុងឱកាសនោះដែរ ឯកឧត្ដមរដ្ឋមន្ត្រី **ជា វ៉ាន់ដេត** បានមានប្រសាសន៍ថា ដើម្បីកសាងរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចឌីជីថល សង្គមឌីជីថល និងពលរដ្ឋឌីជីថល ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ការបង្កើនការអភិវឌ្ឍធនធានមនុស្សជំនាញឌីជីថល គឺជាតម្រូវការចាំបាច់ដែលមិនអាចខ្វះបាន និងមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ក្នុងការបោះជំហានឱ្យក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចឌីជីថល និងរដ្ឋបាលឌីជីថលប្រកបដោយប្រសិទ្ធភាពខ្ពស់។ ស្របជាមួយគ្នានេះ **ឯកឧត្ដមរដ្ឋមន្ត្រី** បានបន្តថា **ក.ប.ទ.** បានបង្កើត "**កម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល**" ដែលកម្មវិធីនេះ នឹងអនុញ្ញាតឱ្យសិស្សដែលមិនមានលទ្ធភាពបង់

ថ្លៃសិក្សា អាចស្នើសុំថវិកាសិក្សាដែលមិនគិតការប្រាក់ សម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រលើជំនាញបច្ចេកវិទ្យាឌីជីថល នៅគ្រឹះស្ថានឧត្តមសិក្សាដៃគូរបស់កម្មវិធី។ និស្សិតត្រូវទូទាត់មកវិញនូវ ២០% នៃប្រាក់បៀវត្សប្រចាំខែ នៅពេលដែលខ្លួនចេញធ្វើការនិងទទួលបានបៀវត្សចាប់ពី ៥០០ដុល្លារអាម៉េរិកឡើងទៅ ដើម្បីទ្រទ្រង់និរន្តរភាពនៃកម្មវិធីសម្រាប់និស្សិតជំនាន់ក្រោយ។ **ឯកឧត្តមរដ្ឋមន្ត្រី** បានបន្ថែមថា កិច្ចសហប្រតិបត្តិការរវាង **ក.ប.ឧ.** និងគ្រឹះស្ថានឧត្តមសិក្សាដៃគូលើថវិកាសិក្សា គឺជាវឌ្ឍនភាពបន្ថែមថ្មីមួយទៀតរបស់ក្រសួង ក្នុងការបន្តអភិវឌ្ឍធនធានមនុស្សលើវិស័យបច្ចេកវិទ្យាឌីជីថល និងផែនការអភិវឌ្ឍមូលធនមនុស្ស ដែលចូលរួមចំណែកដល់ការធ្វើបរិវត្តកម្មឌីជីថល។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានបញ្ជាក់ថា ការលើកកម្ពស់ការអប់រំលើជំនាញបច្ចេកវិទ្យាឌីជីថលប្រកបដោយគុណភាព ជាយុទ្ធសាស្ត្រដ៏សំខាន់មួយនៃបេសកកម្មរបស់ **ក.ប.ឧ.** ក្នុងការធ្វើបរិវត្តកម្មឌីជីថលបម្រើដល់ការអប់រំនៅកម្ពុជា។ **ឯកឧត្តមរដ្ឋមន្ត្រី** ជឿជាក់យ៉ាងមុតមាំថា កម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថលនឹងទទួលបានជោគជ័យ ហើយផ្តល់ផ្លែផ្កាត្រលប់មកវិញនូវមូលធនមនុស្សឌីជីថល ដែលជាកម្លាំងសកម្មក្នុងការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថល ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

**ក.ប.ឧ.** សូមលើកទឹកចិត្តដល់សិស្សនិស្សិតទាំងអស់ ដែលមានតម្រូវការស្នើសុំហិរញ្ញប្បទានសិក្សាពីកម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល អាចទំនាក់ទំនងតាមរយៈលេខទូរសព្ទ ០៩៨ ៩៤៣ ៧៧៧ ឬគេហទំព័រ www.dsdp.gov.kh ឬតាមផានហ្វេសប៊ុកផ្លូវការឈ្មោះ "កម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល" ឬ ស្កេន QR Code ខាងក្រោម។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

០៩៨ ៩៤៣ ៧៧៧ | តេឡេក្រាម | ហ្វេសប៊ុក

គេហទំព័រកម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល www.dsdp.gov.kh